ការជួយកូនឱ្យប្រើប្រាសគណនី **Canvas** ថ្មី**A**

ស្វាគមន៍មកឆ្នាំសិក្សាថ្មី ២០២០-២០២១ ដែលនឹងចាប់ផ្តើមតាមអនឡាញទាំងស្រុង។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីរបៀបដែលលោកអ្នកជួយកូនឱ្យប្រើប្រាស Canvas ដែលជាប្រព័ន្ធគ្រប់គ្រងការសិក្សាថ្មីរបស់យើង ហើយត្រូវតែ ឡុកអ៊ិន ចូលទៅក្នុង មុននឹងលោកអ្នកអាចចុះឈ្មោះជាអ្នកមើលតាមដានកូន។ បន្ទាប់ពីថ្ងៃចូលរៀនដំបូងនៅថ្ងៃទី១កញ្ញា មាតាបិតាអាចភ្ជាប់គណនីគាត់ជាមួយគណនីរបស់កូន។ ព័ត៌មានបន្ថែមអំពីការ ចុះឈ្មោះប្រើប្រាស ឡុកអ៊ិន របស់មាតាបិតានិងមានជូនតាមក្រោយ។

## ការចុះឈ្មោះប្រើប្រាស ឡុកអ៊ិន សម្រាប់សិស្ស

<u>ប្រើកុំព្យូទ័រឬឡេបថប់</u>




1. ចូលទៅគេហទំព័រក្រសួងអប់រំ LBUSD នៅ: lbschools.net

2. ចុចលើពាក្យ **Students** រួចចុចលើពាក្យ **Canvas**

3. ឡុកអ៊ិន ចូលទៅ **Rapid Identity** (ដូចគ្នានឹងក្រូមប៊ុគដែរ)

   ឈ្មោះអ្នកប្រើប្រាស Username: StudentID@student.lbchools.net ឬលេខអត្តសញ្ញាណ៩ខ្ទង់របស់សិស្ស

   ពាក្យសម្ងាត់ Password: ថ្ងៃកំណើត៦ខ្ទង់- ខែថ្ងៃឆ្នាំ MMDDYY (លើកលែងតែសិស្សបានប្តូរវា)

   ចុចពាក្យ **Go**.

   (បើលោកអ្នកត្រូវការជំនួយរកលេខអត្តសញ្ញាណសិស្ស សូមអានទំព័រចុងក្រោយនៃឯកសារនេះ)

4. ទំព័រព័ត៌មានផ្ទាល់ខ្លួនរបស់សិស្សនឹងចេញមកហើយនឹងមានបង្ហាញថ្នាក់របស់កូន។ ចុចញាប់២ដងលើរូបថ្នាក់ណាមួយដើម្បីចូលទៅមើលថ្នាក់នោះ។ ថ្នាក់រៀននឹងមិនមានបង្ហាញនៅក្នុងប្រព័ន្ធ Canvas រហូតដល់ថ្ងៃទី១នៃថ្ងៃចូលរៀន។ (ចំនួនថ្នាក់រៀនដែលមានបង្ហាញគឺអាស្រ័យទៅលើកាលវិភាគរបស់កូន)។ ខាងក្រោមនេះជាគំរូ:




ជួយកូនឱ្យចូលទៅក្នុងគណនី **Canvas** ថ្មីតាមទូរស័ព្ទដៃឬឧបករណ៍ចល័ត

*(ដោនឡូតកម្មវិធី* Student Canvas app *ពីទូរស័ព្ទ Apple ឬប្រព័ន្ធ Android).*




1. ចុចលើពាក្យ **Find my school**.
2. វាយអក្សរ **Long Beach**.
3. រើសយក **Long Beach Unified School District (Teacher/Students/Staff ONLY)**







4. ឡុកអ៊ិនចូលទៅក្នុង **Rapid Identity** (ដូចគ្នានឹងក្រុមប៊ុគដែរ) ;
   ឈ្មោះអ្នកប្រើប្រាស Username: [StudentID@student.lbchools.net](mailto:StudentID@student.lbchools.net) ឬលេខអត្តសញ្ញាណ៩ខ្ទង់របស់សិស្ស
   ពាក្យសម្ងាត់ Password: ថ្ងៃកំណើត៦ខ្ទង់- ខែថ្ងៃឆ្នាំ MMDDYY (លើកលែងតែសិស្សបានប្តូរវា)

ចុចពាក្យ **Go**.

(បើលោកអ្នកត្រូវការជំនួយរកលេខអត្តសញ្ញាណសិស្ស សូមអានទំព័រចុងក្រោយនៃឯកសារនេះ)

ចុចពាក្យ **Reset Password** នៅលើទំព័របន្តភ្ជាប់ portal បើអ្នកមិនចាំពាក្យសម្ងាត់។ ធ្វើតាមការណែនាំអនឡាញ។




5. ថ្នាក់រៀនរបស់កូននឹងមានបង្ហាញនៅលើទំព័រផ្ទាល់ខ្លួនរបស់សិស្ស ចុចលើថ្នាក់មួយណាដើម្បីចូលទៅមើលក្នុងថ្នាក់នោះ

## តើខ្ញុំរកមើលលេខអត្តសញ្ញាណរបស់កូនខ្ញុំនៅកន្លែងណា?

1. សួរកូន បើកូនបានទៅរៀនក្នុងក្រសួងអប់រំ LBUSD កាលពីឆ្នាំមុន។
    - ○ សិស្សប្រើលេខអត្តសញ្ញាណជាញឹកញាប់ នៅសាលាដើម្បីចូលទៅប្រព័ន្ធផ្សេងៗ ដូចជាចូលក្នុងក្រុមប៊ុត ជាដើម្បីយវាមានលេខ៩ខ្ទង់
    - ○ បើសិនជាសិស្សមានប័ណ្ណអត្តសញ្ញាណសិស្ស ដែលសាលាបានចេញឱ្យ លេខអត្តសញ្ញាណសិស្សគឺនៅលើប័ណ្ណនោះ។



2. នៅក្នុង ParentVue លេខអត្តសញ្ញាណសិស្សមាននៅក្នុង ParentVUE.
    - ចូលទៅ https://parentlbusd.lbschools.net/
    - ចុចពាក្យ **Parents** រួចរើសយកពាក្យ **ParentVUE Login**.







    - ដាក់ឈ្មោះអ្នកប្រើប្រាសនិងពាកសម្ងាត់។ ចុចពាក្យ **Login**.
    - គណនីរបស់អ្នកនឹងបើកចេញមក ហើយលេខអត្តសញ្ញាណរបស់កូននឹងចេញមកនៅលើកញ្ចក់កុំព្យូទ័រ។ សូមមើលគំរុខាងក្រោមៈ

ចុចពាក្យ **Reset Password** នៅលើទំព័របន្តភ្ជាប់ ParentVUE បើអ្នកមិនចាំពាក្យសម្ងាត់។ ធ្វើតាមការណែនាំអនទ្បាញ។

